**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សាកលវិទ្យាល័យជាតិគ្រប់គ្រង

National University of Management

## ប្រធានបទស្រាវជ្រាវ

## ស្តីអំពី

# ធាតុសត្យានុម័ត ឬធាតុសម្ភារៈ

*(ធាតុទី២ នៃបទល្មើសព្រហ្មទណ្ឌ)*

## ថ្នាក់: បរិញ្ញាបត្រ

## ជំនាញ: ច្បាប់ពាណិជ្ជកម្ម

## មុខវិជ្ជា: នីតិព្រហ្មទណ្ឌទូទៅ

## សាស្ត្រាចារ្យណែនាំ: ឡាយ ណូរ៉ា

**រៀបរៀងដោយនិស្សិត:**

**សុន តុលា, ខេង សេងហាក់, ជីន សុភក្ត្រ័**

**ឆ្នាំសិក្សា ២០១៤-២០១៥**



www.facebook.com/7khmer
fb : Entertainment And Knowledge

## មាតិកា ទំព័រ

សេចក្តីផ្តើម.....០៤

### សញ្ញាណនៃធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ

ក.អត្ថន័យធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ.....០៧

ខ.ទំនាក់ទំនងរវាងអំពើនិងព្យសនកម្ម ឬ ចំណងហេតុនិងផល.....០៧

### ផ្នែកទី ១ បទល្មើសបានសម្រេច

ក.និយមន័យ.....០៨

ខ.បទល្មើសសកម្ម.....០៩

ខ.១.និយមន័យ.....០៩

ខ.២.ចិរវេលានៃបទល្មើសសកម្ម.....១០

គ.បទល្មើសអកម្ម.....១១

គ.១.និយមន័យ.....១១

គ.២.មូលដ្ឋាននៃការកំណត់ជនណាម្នាក់ប្រព្រឹត្តបទល្មើសអកម្ម.....១៣

គ.៣.បទល្មើសមួយចំនួនស្តែងឡើងជាបទល្មើសអកម្ម(ច្បាប់បារាំង).....១៤

សន្និដ្ឋាន.....១៤

### ផ្នែកទី ២ បទល្មើសមិនបានសម្រេច

ក.និយមន័យ.....១៥

ខ.ការប៉ុនប៉ង ឬ បំណាង.....១៦

ខ.១.លក្ខខណ្ឌនៃការប៉ុនប៉ង.....១៦

ខ.២.ទណ្ឌកម្មនៃការប៉ុនប៉ង.....១៩

ខ.២.១.ចំពោះបទឧក្រិដ្ឋ.....១៩

ខ.២.២.ចំពោះបទមជ្ឈិម.....១៩

ខ.២.៣.ចំពោះបទលហុ.....២០

គ.ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស.....២១

គ.១.ដំណាក់កាលនៃការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើស.....២២

គ.២.ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស.....២៣

គ.៣.ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស.....២៦



www.facebook.com/7khmer
fb : Entertainment And Knowledge

គ.៤.ដំណាក់កាលនៃការសម្រេចបទល្មើស ឬ បទល្មើសប៉ុនប៉ង(បទល្មើសមិនបានសម្រេចក្លាយ ជាការប៉ុនប៉ង)........................................................................................................២៦
សន្និដ្ឋាន....................................................................................................................២៨
សេចក្តីសន្និដ្ឋានរួម......................................................................................................២៩
ឯកសារយោង..............................................................................................................៣០



www.facebook.com/7khmer
fb : Entertainment And Knowledge

# សេចក្តីផ្តើម

យោងតាមព្រះរាជក្រមលេខ នស/រកម /១១០៩/០២២ ប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១២ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើក ទី ៣ នីតិកាលទី ៤ និង ព្រឹទ្ធសភា ក៏បានយល់ស្របតាមទម្រង់និងគតិច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញ អង្គព្រឹទ្ធសភាលើកទី ៦ នីតិកាទី ២ ហើយត្រូវបានព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ជា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាយើងទ្រង់បានឡាយ ព្រះហស្តលេខាប្រកាសឲ្យ ប្រើក្រមព្រហ្មទណ្ឌថ្មីចាប់តាំងពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។ នៅក្នុងក្រមព្រហ្មទណ្ឌថ្មី របស់ខ្មែរយើងនេះ គឺមានចែងអំពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានគេចាត់ថ្នាក់បទល្មើស ទាំងអស់នោះជាបីរគឺជាបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម និងបទល្មើសលហុ ។ គ្រប់បទ ល្មើសទាំងបីរនេះសុទ្ធតែមានធាតុផ្សំដូចៗគ្នា ហើយធាតុផ្សំបទល្មើសព្រហ្មទណ្ឌត្រូវបានចែក ចេញជាបីរគឺធាតុនីត្យានុកូល ឬធាតុច្បាប់ ធាតុសត្យានុម័ត ឬធាតុសម្ភារ: និង ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ ។ ធាតុនីត្យានុកូល ឬធាតុច្បាប់ និងធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រក្រុម របស់ខ្ញុំ សូមមិនពន្យល់ឬបកស្រាយទេដោយហេតុថាធាតុនីត្យានុកូល ឬធាតុច្បាប់និងធាតុ អត្តនោម័តឬធាតុចិត្តសាស្ត្រទាំងពីរធាតុនេះ គឺមានមិត្តនិស្សិតក្រុមផ្សេងគាត់បានធ្វើការ ស្រាវជ្រាវ និងពន្យល់បកស្រាយរួចមកហើយ ប្រសិនបើចង់ដឹងបន្ថែមពីធាតុផ្សំទាំងពីរនេះ អាចរកឯកសារស្រាវជ្រាវរបស់ក្រុមគាត់បាន ។

នៅពេលនេះផងដែរ ក្រុមរបស់ខ្ញុំនឹងធ្វើការពន្យល់បកស្រាយតាមតែអាចធ្វើទៅ បានអំពីធាតុសត្យានុម័ត ឬធាតុសម្ភារ: ។ ក្នុងចំណោមធាតុផ្សំទាំងបីរនៃបទល្មើសមានធាតុ នីត្យានុកូល ឬធាតុច្បាប់ ធាតុសត្យានុម័ត ឬធាតុសម្ភារ: ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ យើងសង្កេតឃើញថា ធាតុសត្យានុម័ត ឬយើងអាចហៅម្យ៉ាងទៀតថា ធាតុសម្ភារ:ត្រូវបាន អ្នកសិក្សាផ្នែកច្បាប់ទូទៅបានមូលមតិគ្នាលើកឡើងថា ធាតុសត្យានុម័ត ឬធាតុសម្ភារ: គឺជា ធាតុ ដែលមានសារ:សំខាន់ខ្លាំងណាស់ដែលយើងទាំងអស់គ្នា មិនអាចមើលរំលងបានទេ



www.facebook.com/7khmer
fb : Entertainment And Knowledge

ប្រយោជន៍ដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីបទល្មើសណាមួយ ដែលកើតឡើងដោយអំពើប្រព្រឹត្តរបស់ជនណាម្នាក់ ។

គោលបំណងនៃការស្រាវជ្រាវ ទៅលើប្រធានបទ "ធាតុសត្យានុម័ត ឬធាតុសម្ភារៈ" គឺចង់ឆ្លុះបញ្ចាំងឲ្យឃើញពីអំពើប្រព្រឹត្តរបស់ជនល្មើសទោះដោយសកម្ម ឬដោយអកម្មក្តីដែលអំពើទាំងអស់នោះសុទ្ធតែបានជះឥទ្ធិពល យ៉ាងខ្លាំងដល់ សិទ្ធិសេរីភាព បូរណភាព បុគ្គល ទ្រព្យសម្បត្តិសាធារណៈ ឬឯកជនជាដើម ។

ដើម្បីឲ្យយល់កាន់តែច្បាស់ពីធាតុសត្យានុម័តឬធាតុសម្ភារៈយើងគួរគប្បីត្រូវតែយល់ដឹងអំពីថាតើធាតុសត្យានុម័ត ឬធាតុសម្ភារៈមានអត្ថន័យដូចម្តេចខ្លះ ? តើធាតុសត្យានុម័ត ឬធាតុសម្ភារៈនេះស្តែងឡើងតាមរយៈអ្វី ? តើវាមានសារៈសំខាន់ដូចម្តេច ដើម្បីកំណត់នូវបទល្មើសណាមួយ ? តើធាតុសត្យានុម័ត ឬធាតុសម្ភារៈនេះវាជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះចំពោះសង្គមជាតិ ?

ទន្ទឹមនឹងនេះផងដែរ មូលហេតុដែលជំរុញឱ្យក្រុមរបស់ខ្ញុំសម្រេចចិត្តមូលមតិគ្នាជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវដោយសារមានកត្តាពីយ៉ាង គឺកត្តាខាងក្នុង ឬកត្តាខ្លួនឯង មានន័យថាក្រុមរបស់ខ្ញុំមានឆន្ទៈដូចគ្នាក្រោយពីមានការពិភាក្សាដេញដោលជាមួយគ្នាក្នុងការជ្រើសរើសប្រធានបទនេះមកធ្វើការស្រាវជ្រាវជាប្រយោជន៍ គឺដើម្បីពង្រីកនូវចំណេះដឹងផ្នែកច្បាប់ឱ្យកាន់តែទូលំទូលាយថែមទៀត ។ រីឯកត្តាទីពីរគឺកត្តាខាងក្រៅត្រង់ចំណុចនេះ គឺចង់មានន័យថា បន្ទាប់ពីពួកខ្ញុំមានឆន្ទៈដូចគ្នាក្នុងការជ្រើសរើសប្រធានបទមួយនេះមកធ្វើការស្រាវជ្រាវរួចលេចចេញជាឯកសារមួយឡើង ក៏មានការជួយជំរុញលើកទឹកចិត្តនិងមានការចង្អុលបង្ហាញបន្ថែមពីសំណាក់លោកគ្រូសាស្ត្រាចារ្យ **ឡាយ ណូរ៉ា** ដែលជាសាស្ត្រាចារ្យបង្រៀន "នីតិព្រហ្មទណ្ឌ" ផងដែរទើបក្រុមរបស់ខ្ញុំជ្រើសរើស ប្រធានបទ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ មកធ្វើការសិក្សាស្រាវជ្រាវតែម្តង ។

ចំពោះឯកសារយោងវិញ ដែលក្រុមរបស់ខ្ញុំយកមកសំយោគ ដើម្បីឲ្យការស្រាវជ្រាវមានភាពរលូន និងសម្រេចចេញជាឯកសារនេះឡើង ហើយអត្ថន័យនៃប្រធានបទមានលក្ខណៈត្រឹមត្រូវសមស្របតាមគតិច្បាប់ គឺពួកខ្ញុំទាំងអស់គ្នាបានខិតខំយ៉ាងសស្រាក់សស្រាំ



www.facebook.com/7khmer
fb : Entertainment And Knowledge

ទាំងយប់ទាំងថ្ងៃ ក្នុងការស្វែងរកឯកសារផ្សេងដែលពាក់ព័ន្ធទៅ និងប្រធានបទ ។ ឯកសារទាំងអស់នោះពួកខ្ញុំបានមកពី បណ្ណាគារ បណ្ណាល័យជាតិ បណ្ណាល័យសកលវិទ្យាល័យជាតិគ្រប់គ្រង ( NUM ) បណ្ណាល័យ ហ៊ុន សែន សៀវភៅសារណា សៀវភៅ Assignment របស់និស្សិតច្បងជំនាន់មុនៗ សៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់សាស្ត្រាចារ្យមួយចំនួនទៀត ។ ជាងនេះទៅទៀតក្រៅពី ឯកសារសរសេរ ក៏មានឯកសារជា សំដីដែលសុទ្ធតែជាប្រសាសន៍ដោយផ្ទាល់មាត់របស់លោកគ្រូសាស្ត្រាចារ្យ **ឡាយ ណូរ៉ា** មានជំនាញនិងបង្រៀនក្រមព្រហ្មទណ្ឌផ្ទាល់តែម្តង ។

យើងជឿជាក់ក្នុងចិត្តយ៉ាងមុតមាំថា ប្រធានបទ "ធាតុសត្យានុម័ត ឬធាតុសម្ភារៈ" នេះពិតជាផ្តល់នូវអត្ថប្រយោជន៍ជាប្រាកដដល់អ្នកសិក្សាទូទៅ ដែលគាត់មានបំណងចង់ចេះ ចង់ដឹង ចង់យល់អំពីច្បាប់នៃប្រទេសកម្ពុជាយើងជាពិសេស គឺក្រមព្រហ្មទណ្ឌថ្មីនេះតែម្តង ដែលជាច្បាប់ ទើបតែប្រកាសឲ្យប្រើ ហេតុដូច្នេះហើយរាល់ការយល់អំពីអត្ថន័យនៃបទប្បញ្ញត្តិនៅក្នុងមាត្រានីមួយៗ នៃក្រមព្រហ្មទណ្ឌថ្មី គឺពិតនៅមានកម្រិតនៅឡើយ ។ បន្ថែមពីលើនេះឯកសារដ៏តូចនេះក៏ផ្តល់ផលប្រយោជន៍ដល់សាស្ត្រាចារ្យ ដែលគាត់បង្រៀននៅតាមសាលាផ្សេងៗផ្នែកច្បាប់ ឬក្រមព្រហ្មទណ្ឌថ្មីនេះតែម្តងគឺពួកគាត់ អាចយកឯកសារដ៏តូចនេះទៅសម្របសម្រួលកែតម្រូវបន្ថែមដោយសំយោគជាមួយឯកសារផ្សេងៗ យកតែកន្លែងសមស្របទៅតាមគតិច្បាប់ជាប្រយោជន៍ ដើម្បីយកទៅបង្រៀនដល់សិស្ស និស្សិតដែលរៀនផ្នែកច្បាប់ផ្ទាល់តែម្តង ។

ជាងនេះទៅទៀត ឯកសារនេះក៏មានប្រយោជន៍ដល់និស្សិត ដែលសិក្សាផ្នែកច្បាប់ផ្ទាល់តែម្តង គឺពួកគាត់អាចយក ឯកសារនេះទៅសិក្សាបន្ថែមនិងដើម្បីពង្រីកនូវចំណេះដឹងផ្នែកច្បាប់របស់ពួកគាត់បន្ថែមទៀតឱ្យកាន់តែទូលំទូលាយថែមមួយកម្រិតទៀត ។ ពិសេសយើងសង្ឃឹមយ៉ាងមុតមាំថាឯកសារ ដែលប្រសូត្រចេញពីការខិតខំស្រាវជ្រាវរបស់យើងនេះ ទោះវាមានលក្ខណៈតិចតួច ឬស្តួចស្តើងក្តី វានឹងបានជាប្រយោជន៍ និងចូលរួមចំណែកដល់សង្គមកម្ពុជាយើងក្នុងការលើកកំពស់នូវប្រព័ន្ធច្បាប់ពង្រីកនូវប្រព័ន្ធយុត្តិធម៌ ឱ្យកាន់តែមានភាពសុក្រិតថែមទៀតផងដែរ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

# សញ្ញាណធាតុសត្យានុម័ត ឬធាតុសម្ភារៈ

## ក.អត្ថន័យនៃធាតុសត្យានុម័ត ឬធាតុសម្ភារៈ

ធាតុសត្យានុម័ត ឬធាតុសម្ភារៈ គឺជាអំពើប្រព្រឹត្តទាំងឡាយ ទោះដោយសកម្ម ឬជាអំពើអកម្មក្តី ដែលអំពើទាំងអស់នោះមានផលប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាព បុគ្គល ទ្រព្យសម្បត្តិសាធារណៈ ឬឯកជនជាដើម ។

ធាតុសត្យានុម័ត ឬបើយើងហៅតាមបែបសាមញ្ញថាជាធាតុសម្ភារៈ មានន័យថាជាសកម្មភាព ដែលកើតចេញរួចធ្វើឱ្យគេអាចសង្កេតឃើញនឹងភ្នែកជាក់ស្តែងតាមរយៈសម្ភារៈខាងក្រៅ ។ ដោយហេតុនេះហើយទើបបានជានៅក្នុងទ្រឹស្តី គេតែងតែនិយមហៅធាតុផ្សំសត្យានុម័តថាជាធាតុសម្ភារៈនៃបទល្មើស[១] ។ ធាតុសត្យានុម័ត ឬធាតុសម្ភារៈជាធាតុផ្សំ ដែលមានសារៈសំខាន់មិនអាចខ្វះបាន ព្រោះថាប្រសិនបើមនុស្សម្នាក់ៗ មិនប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់ ឬអំពើ ដែលត្រូវច្បាប់ដាក់បម្រាមហាមឃាត់នោះទេ វាប្រាកដជាគ្មានបច្ច័យអាក្រក់កើតឡើងដែរ ។

## ខ. ទំនាក់ទំនងរវាងអំពើនិងព្យសនកម្ម ឬចំណងហេតុនិងផល

ដើម្បីអាចកំណត់បានថា អំពើណាមួយជាបទល្មើស គឺទាល់តែមានអំពើស្តែងចេញឡើង ហើយមានចរិតគ្រោះថ្នាក់ស្តែងចេញមកខាងក្រៅ ដែលយើងអាចមើលឃើញនឹងភ្នែកតាមរយៈអំពើជាសត្យានុម័ត ។ ព្យសនកម្ម (ការខូចខាត) ត្រូវមានទំនាក់ទំនងរវាងគ្នានិងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងអំពើប្រព្រឹត្តរបស់ជនល្មើស ។

ឧទាហរណ៍ មានករណីឃាតកម្មមួយ បានកើតឡើងដោយជនល្មើស ឬជនដៃដល់បានយកកាំភ្លើងរបស់ខ្លួនម៉ាក k.59 ទៅបាញ់សម្លាប់ជនរងគ្រោះម្នាក់ ។ ត្រង់ចំណុចនេះចង់បញ្ជាក់ថា នៅលើដងខ្លួនរបស់ជនរងគ្រោះ ដែលត្រូវជនល្មើសបានបាញ់សម្លាប់ដោយប្រើកាំភ្លើងជាអាវុធ គឺដាច់ខាតត្រូវតែមាននូវស្លាកស្នាមគ្រាប់កាំភ្លើងចូលក្នុងរូបកាយ ហើយបណ្តាល

---

[១] ប្រសាសន៍របស់ឯកឧត្តម កេត រិទ្ធ អានុប្រធានក្រុមការងារចូលរួមតាក់តែងនឹងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងពត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ២០១០



www.facebook.com/7khmer
fb : Entertainment  And Knowledge

ឱ្យស្លាប់បាត់បង់ជីវិត ។ ចំណែកឯគ្រាប់កាំភ្លើងវិញ គឺត្រូវតែជាគ្រាប់ប្រភេទកាំភ្លើង k.59 ដែលជនល្មើសយកមកធ្វើជាអាវុធ ដើម្បីបាញ់សម្លាប់ជនរងគ្រោះ បើមិនដូចនោះទេ គេពិតជាមិនអាចបង្ខំឱ្យជនល្មើសទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ។

ក្នុងករណីខ្លះទៀត ជនរងគ្រោះអាចទទួលនូវព្យសនកម្ម ដែលមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងអំពើប្រព្រឹត្តដែរ ។

ឧទាហរណ៍៖ ករណីរឿងគ្រោះថ្នាក់ចរាចរណ៍ ក្រោយពីមានគ្រោះថ្នាក់កើតឡើងហើយជនរងគ្រោះដែលជាអ្នកមានស្តុកស្តម្ភមានពាក់គ្រឿងអលង្ការមាសពេជ្រជ្រែកខ្លួននិងមានប្រាក់កាសច្រើនរាប់ពាន់ដុល្លារក្នុងកាបូបផងដែរ នៅពេលកំពុងមានគ្រោះថ្នាក់នោះមានមនុស្សជាច្រើនចោមរោមមើល ។ ស្របពេលជាមួយគ្នានេះមានជនឆក់ឱកាសឆ្លៀតពេលកំពុងមានមនុស្សផ្អើលមកមើលឈ្ងរឆេរ ក៏បានទៅដោះយកគ្រឿងអលង្ការ និងប្រាក់ក្នុងកាបូបអស់រលីងពីជនរងគ្រោះ ដែលធ្វើឱ្យជនរងគ្រោះក្រោកឡើងអង្គុយយំស្តាយទ្រព្យសម្បត្តិ ដែលខ្លួនបានបាត់បង់ ។

## ផ្នែកទី១ បទល្មើសបានសម្រេច

### ក. និយមន័យ

បទល្មើសបានសម្រេច គឺជាបទល្មើសទាំងឡាយណា ដែលជនល្មើស ឬជនដៃដល់បានបំពេញនូវគោលដៅ ឬគោលបំណងរបស់ខ្លួនបានសម្រេច ។ បទល្មើសបានសម្រេចនេះបានបំពេញចិត្ត ស្របតាមចេតនា ឬឆន្ទៈរបស់ជនល្មើស ឬជនដៃដល់ដោយផ្តល់នូវបច្ច័យអាក្រក់ ឬផលអាក្រក់ដល់ជនរងគ្រោះ ។

ឧទាហរណ៍ទី១៖ នៅកន្លែងផឹកស៊ីមួយ មានរឿងឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងរវាងភាគីម្ខាង គឺលោក-ក ភាគីម្ខាងទៀត គឺលោក-ខ ។ ដោយមានទឹកប្ញូវនិស្ស័យ (ស្រា...) នៅក្នុងខ្លួនផង អ្នកទាំងពីរនិយាយមិនត្រូវគ្នាទេ គឺរឹតតែក្តៅស្លឹកត្រចៀករៀងៗខ្លួន ។ លោក-កដោយមានកំហឹងចំពោះលោក-ខខ្លាំងពេកមិនអាចអត់ទ្រាំបាន ក៏យកដបស្រាទៅបោកនឹងតុបាក់ដាច់ពាក់កណ្តាល ហើយយកដបស្រា ដែលសល់ពាក់កណ្តាលមានមុខមុតស្រួចទៅ



www.facebook.com/7khmer
fb : Entertainment And Knowledge

ចាក់លើពោះលោក-ខ បណ្ដាលឱ្យលោក-ខ រយៈពោះដាច់ពោះវៀនហូរឈាមខ្សោះខ្លួនស្លាប់មួយរំពេច ។

ឧទាហរណ៍ទី២៖ មានបុរសម្នាក់ ឈ្មោះលោក-ក ជាមនុស្សញៀនក្នុងរឿងកាម-គុណឃើញ គឺមិនបានទេស្រីៗ មិនថាចាស់ ឬក្មេងឡើយ ។ នៅថ្ងៃមួយមាននារីម្នាក់ឈ្មោះនាង-ខកំពុងដើរតាមផ្លូវស្ងាត់តែម្នាក់ឯង ដោយបុរសញៀនកាម គឺលោក-ក បានឃើញដូចនោះ ក៏មានចិត្តចង់ចាប់រំលោភសេពសន្ថវៈលើរូបនាង-ខ ។ ដោយអត់ទ្រាំមិនបាន ព្រោះតែសម្រស់នាង-ខស្រស់ស្អាតពេក និងមាននិស្ស័យចង់ដេកគុកផង លោក-ក ភ្លាមនោះក៏ស្ទុះទៅចាប់នាង-ខ អូសចូលព្រៃ ហើយបានចាប់រំលោភសេពសន្ថវៈលើរូបនាង-ខរហូតបានសម្រេចជាស្ថាពរ ។

យោងតាមឧទាហរណ៍ទាំងពីរខាងលើនេះ យើងឃើញថាអំពើប្រព្រឹត្តរបស់ជនល្មើស ឬជនដៃដល់ទាំងពីរ គឺសុទ្ធតែបានសម្រេចតាមបំណងប្រាថ្នារបស់ខ្លួន ហើយវាបានផ្ដល់នូវបច្ច័យអាក្រក់ដល់ជនរងគ្រោះទាំងពីរនោះដែរ នេះហើយគឺជាបទល្មើសបានសម្រេច ។

បទល្មើសបានសម្រេច គឺបានស្ដែងឡើងក្រោមរូបភាពពីរយ៉ាង ដែលក្រុមរបស់ខ្ញុំនឹងធ្វើការវិភាគបកស្រាយដូចខាងក្រោមនេះ ។

## ខ. បទល្មើសសកម្ម

### ខ.១. និយមន័យ

បទល្មើសសកម្ម គឺជាបទល្មើស ដែលជនល្មើស ឬជនដៃដល់ប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌបានហាម ។

បទល្មើសសកម្ម គឺជាសកម្មភាពប្រព្រឹត្តយ៉ាងខិតខំរបស់ជនល្មើស ឬជនដៃដល់បំពារបំពានលើទំនាក់ទំនងសង្គម ដែលនីតិព្រហ្មទណ្ឌបានការពារ ។

បទល្មើសសកម្ម គឺជាអំពើដែលស្ដែងចេញពីសកម្មភាពនៃកាយវិការរបស់ជនល្មើសមានន័យថា ជនល្មើស ឬជនដៃដល់ បានប្រព្រឹត្តអំពើចេញជាក់ស្ដែង ដែលអ្នកណាក៏មើលឃើញថាបុគ្គលនោះបានប្រព្រឹត្តដែរ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

ឧទាហរណ៍ទី១៖ ករណីអំពើមនុស្សឃាត ឬបទឃាតកម្មតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មានបុរសម្នាក់ឈ្មោះលោក-ក បានទៅសម្លាប់បុរសម្នាក់ទៀតឈ្មោះ លោក-ខដោយប្រើកាំបិតចាក់ធ្លាយពោះត្រង់នេះ គឺថាអំពើឃាតកម្ម ដែលលោក-ក ទៅសម្លាប់លោក-ខ បានបង្ហាញឱ្យឃើញនូវសកម្មភាពជាសត្យានុម័តមកខាងក្រៅ ដែលបញ្ជាក់យ៉ាងច្បាស់ថាលោក-ក ជាជនល្មើស ឬជនដៃដល់ដោយបានប្រព្រឹត្តអំពើល្មើស គឺសម្លាប់លោក-ខដែលជាជនរងគ្រោះ ។

ឧទាហរណ៍ទី២៖ ក្នុងករណីអំពើបង្ករបួសស្នាមលើរូបកាយដោយជនល្មើស ឬជនដៃដល់បានប្រើដំបងដែកជ្រុងទៅវាយសំពងលើជនរងគ្រោះ បណ្តាលឱ្យជនរងគ្រោះរងនូវរបួសលើរូបរាងកាយជាទម្ងន់ ។

ឧទាហរណ៍ទី៣៖ ក្នុងករណីអំពើលួច តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ជនល្មើសបានទៅលួចទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**ខ.២. ថិរវេលានៃបទល្មើសសកម្ម**

-បទល្មើសសកម្ម អាចជាអំពើប្រព្រឹត្ត ដែលកើតឡើងតែមួយភ្លែត ក្នុងរយៈពេលខ្លីហើយសាមញ្ញផងដែរ ។

ឧទាហរណ៍ទី១៖ អំពើលួចកាបូបលុយក្នុងហោប៉ៅខោ គឺថាជនល្មើស ឬជនដៃដល់ដើរសសៀរជិតជនរងគ្រោះរួចក៏លូកដៃទៅក្នុងហោប៉ៅខោរបស់ជនរងគ្រោះដើម្បីនឹងលួចយកកាបូបលុយ ហើយរត់គេចខ្លួនបាត់ស្រមោលទៅ ។

ឧទាហរណ៍ទី២៖ ទាក់ទងនឹងការបាញ់សម្លាប់មនុស្ស មានជនល្មើសពីរនាក់ជិះម៉ូតូអត់ស្លាកលេខប្រដាប់ដោយកាំភ្លើងខ្លី K.59 បានជិះម៉ូតូមកឈប់នៅមុខផ្ទះជនរងគ្រោះ ហើយជនល្មើស ដែលជិះខាងក្រោយក៏ដកកាំភ្លើងបាញ់ទៅលើជនរងគ្រោះ ដែលកំពុងអង្គុយលេងមុខផ្ទះ ។ ក្រោយពីបាញ់ត្រូវ ជនរងគ្រោះដេកក្នុងថ្លុកឈាម ជនល្មើសក៏ប្រញាប់ប្រញាល់ជិះម៉ូតូរត់គេចខ្លួនមួយរំពេច ។

យើងសង្កេតឃើញថា ជនល្មើសទាំងពីរករណីខាងលើនេះ សុទ្ធតែប្រើរយៈពេលខ្លីដូចគ្នាក្នុងការប្រព្រឹត្តបទល្មើសពីរផ្សេងគ្នា ដែលយើងមិនអាចគិតស្មានដល់ ។



www.facebook.com/7khmer
fb : Entertainment  And Knowledge

-ករណីខ្លះទៀតបទល្មើសសកម្មអាចអូសបន្លាយពេលវេលា ឬមានរយ:ពេលយូរ ។

ឧទាហរណ៍៖ ការទទួលផលចោរកម្ម ករណីនេះបទល្មើស មិនមែនកើតឡើងដោយប្រើរយ:ពេលខ្លីនោះទេ គឺវាមានរយ:ពេលយូរ ព្រោះថាអ្នកទទួលផលចោរកម្ម គាត់មិនបានប្រព្រឹត្តអំពើល្មើសដោយផ្ទាល់ដៃខ្លួនឯងទេ គឺចាំទទួលផលចោរកម្មពីជនល្មើស ដែលទៅប្រព្រឹត្តអំពើចោរកម្មដោយផ្ទាល់ រួចយកមកលក់ឱ្យអ្នកទិញរបស់អ្នកដែលបានពីអំពើចោរកម្ម ។

បទល្មើសសកម្មនេះ អាចប្រព្រឹត្តដោយជនល្មើសផ្ទាល់តែម្តង ឬតាមរយ:អំពើរបស់ភ្នាក់ងារកណ្តាល ។

ឧទាហរណ៍ទី១៖ ទាក់ទងនឹងអំពើលួច ជនល្មើសឈ្មោះលោក-ក បានទៅលួចម៉ូតូរបស់អ្នកដទៃ ដែលនៅជិតខាងនឹងគ្នា ។ ក្រោយពីលួចបានម៉ូតូហើយជនល្មើស គឺលោក-ក ហ្នឹងឯងក៏បានយកម៉ូតូទៅលក់បាត់ទៅ ។ ត្រង់ចំណុចនេះ គឺចង់បញ្ជាក់ថា បទល្មើសលួចម៉ូតូនេះ គឺជនល្មើសជាអ្នកប្រព្រឹត្តដោយផ្ទាល់ ។

ឧទាហរណ៍ទី២៖ ចំពោះអំពើលួចដូចគ្នាដែរ ជនល្មើសជាអនីតិជនអាយុក្រោម ១៨ ឆ្នាំ បានទៅលួចម៉ូតូគេក្រោមការបង្គាប់បញ្ជារបស់បងធំរបស់ខ្លួន ដើម្បីយកម៉ូតូនោះទៅលក់យកលុយមកទិញគ្រឿងញៀនសម្រាប់ប្រើប្រាស់ ។ ត្រង់ចំណុចនេះវិញ គឺចង់បញ្ជាក់ថា ជនល្មើសផ្ទាល់មិនមានគំនិតចង់ទៅលួចម៉ូតូគេនោះទេ ប៉ុន្តែដោយគ្មានជម្រើស ព្រោះថាបងធំរបស់ខ្លួនបានបញ្ជាឱ្យខ្លួន (ជនល្មើស) ទៅលួចម៉ូតូគេយកទៅឱ្យបងធំ ដើម្បីលក់បានលុយទិញគ្រឿងញៀនប្រើប្រាស់ ។ ជនល្មើសអាយុក្រោម ១៨ ឆ្នាំនេះ ហើយដែលគេហៅថាភ្នាក់ងារកណ្តាល ។

### គ. បទល្មើសអកម្ម

### គ.១. និយមន័យ

បទល្មើសអកម្ម គឺជាបទល្មើសដែលជនល្មើសមិនព្រមបំពេញកាតព្វកិច្ចអ្វីមួយទៅតាមច្បាប់ព្រហ្មទណ្ឌតម្រូវ ។ នៅក្នុងបទល្មើសអកម្មនេះ គឺថាយើងមានលទ្ធភាពគ្រប់គ្រាន់នឹងធ្វើដែរ តែយើងបែរជាមិនព្រមបំពេញទៅវិញ ឬយើងបានបំពេញដែរ តែមិនបានពេញ



www.facebook.com/7khmer
fb : Entertainment And Knowledge

លេញតាមការកំណត់របស់ច្បាប់ ឬមួយក៏យើងភ្លេចមិនបានបំពេញតែម្តង ។ យ៉ាងណាមិញ យើងគួរចាំថា ទាល់តែមានច្បាប់ចែងជាក់លាក់ថាកាតព្វកិច្ចណាខ្លះ ដែលបុគ្គលគ្រប់រូបក្នុងសង្គម ឬបុគ្គលណាខ្លះត្រូវបំពេញ ហើយនៅពេលអាក់ខានមិនបានបំពេញតាមច្បាប់កំណត់នោះទេ បុគ្គលនេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ គឺចង់មានន័យថា បុគ្គលនោះត្រូវតែទទួលខុសត្រូវពីអំពើរបស់ខ្លួនដែលជាបទល្មើស ។

ឧទាហរណ៍ទី១៖ បទមិនប្តឹងបរិហារបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងមាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌថ្មី ដែលក្នុងនេះបានចែងថា "រាល់បុគ្គលណា ដែលដឹងពីបទឧក្រិដ្ឋដែលអាចនឹងបង្ការ ឬបន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនបានប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០,០០០ (មួយសែន) រៀល ទៅ ២,០០០,០០០ (ពីរលាន) រៀល" ។ នេះគឺជាអំពើអកម្ម ដែលយើងបញ្ជាក់ថាជនម្នាក់នោះ បានដឹងយ៉ាងច្បាស់ថាមានបទឧក្រិដ្ឋនឹងកើតឡើង ក៏ប៉ុន្តែគាត់បែរជាអាក់ខានមិនបានប្តឹងបរិហារពីអំពើនេះទៅអាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចទេ ក្នុងករណីនេះ គឺច្បាប់បានកំណត់ថាអ្នកដែលបានដឹងពីអំពើហ្នឹង ត្រូវមានកាតព្វកិច្ចប្តឹង បើសិនគាត់មិនបានប្តឹងនោះទេ គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថាគាត់ត្រូវមានទោសដាក់គុក និងពិន័យជាប្រាក់ផងដែរទៅតាមបញ្ញត្តិនៃមាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌថ្មី ។

ឧទាហរណ៍ទី២៖ ច្បាប់ស្តីពីកាតព្វកិច្ចយោធាបានចែងថា ប្រជាពលរដ្ឋភេទប្រុសគ្រប់រូប ដែលមានអាយុ ១៨ ឆ្នាំ ឡើងទៅ ត្រូវចូលបម្រើក្នុងជួរកងទ័ពរយៈពេល ១៨ ខែ ។ ប្រសិនបើយើងមានអាយុគ្រប់ ១៨ ឆ្នាំ ហើយស្របតាមច្បាប់កំណត់ថាត្រូវជាប់កាតព្វកិច្ចយោធា ប៉ុន្តែយើងបែរជាប្រឹងរត់គេចវេសមិនព្រមចូលបម្រើក្នុងជួរកងទ័ពទៅវិញ ។ ត្រង់នេះគេអាចធ្វើការចោទប្រកាន់យើងពីបទល្មើសអកម្ម ព្រោះថាច្បាប់បានតម្រូវកាតព្វកិច្ចឱ្យយើងរួចហើយ ហើយយើងខ្លួនឯងក៏មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញនូវកាតព្វកិច្ចនេះដែរ (គ្រប់អាយុតាមការកំណត់របស់ច្បាប់គឺ ១៨ ឆ្នាំ) ក៏ប៉ុន្តែយើងចចេសមានះមិនព្រមបំពេញកាតព្វកិច្ចនោះ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

ឧទាហរណ៍ទី៣៖ ឧបមាថាយើងជាវេជ្ជបណ្ឌិត គឺយើងមានតួនាទីសង្គ្រោះអ្នកជំងឺ ។ នៅពេលមានអ្នកជំងឺធ្ងន់ធ្ងរម្នាក់ ត្រូវបានគេបញ្ជូនមកមន្ទីរពេទ្យដោយអ្នកជំងឺនោះជាជនក្រីក្រគ្មានប្រាក់សូម្បីតែមួយកាក់មួយសេន យើងបែរជាប្រកាន់មិនជួយសង្គ្រោះដោយសារអ្នកជំងឺនោះគ្មានប្រាក់បង់ឱ្យ ។ ដោយសារភាពព្រងើយកន្តើយ មិនព្រមអើពើរបស់យើងជាគ្រូពេទ្យរួមផ្សំជាមួយរបួសកាន់តែធ្ងន់មិនស្រាក អ្នកជំងឺក៏បានយំស្រែកអង្វរគ្រូពេទ្យឱ្យជួយរហូតដាច់ខ្យល់ស្លាប់បាត់បង់ជីវិតទៅ ។ ក្នុងករណីនេះយើងជាគ្រូពេទ្យ នឹងត្រូវបានគេចោទប្រកាន់ពីបទល្មើសអកម្មដោយសារច្បាប់តម្រូវឱ្យគ្រូពេទ្យមានកាតព្វកិច្ចសង្គ្រោះអ្នកជំងឺ ប៉ុន្តែយើងបែរជាអាក់ខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញ ។

**គ.២. មូលដ្ឋាននៃការកំណត់ជនណាម្នាក់ប្រព្រឹត្តបទល្មើសអកម្ម**

ដើម្បីកំណត់ថា ជនណាម្នាក់ប្រព្រឹត្តបទល្មើសអកម្ម យើងត្រូវផ្អែកលើមូលដ្ឋានពីរជាចម្បងគឺ

-ជននោះមានកាតព្វកិច្ចត្រូវបំពេញដោយមានកំណត់នៅក្នុងច្បាប់ ។

-ជននោះមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចនេះ ប្រសិនបើជននោះមិនមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ទេ នោះច្បាប់ក៏មិនតម្រូវឱ្យគាត់ទទួលខុសត្រូវចំពោះច្បាប់ព្រហ្មទណ្ឌដែរ ។ ឧទាហរណ៍៖ ករណីមានអ្នកលង់ទឹកទន្លេ កំពុងលង់ទឹកប្រវេប្រវ៉ាហៅគេឱ្យជួយ នៅពេលនោះយើងជាមនុស្សតែម្នាក់ ដែលបានឃើញព្រឹត្តិការណ៍នោះ ។ ប្រសិនបើយើងមានលទ្ធភាពគ្រប់គ្រាន់អាចជួយសង្គ្រោះអ្នកលង់ទឹកបាន (ចេះហែលទឹកយ៉ាងជំនាញ) ហើយយើងមិនបានទៅជួយសង្គ្រោះអ្នកលង់ទឹកទេដោយឈរមើលរហូតអ្នកនោះលិចក្នុងទឹកបាត់លេបទឹកស្លាប់ទៅ ។ ករណីនេះយើងនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ព្រោះច្បាប់តម្រូវឱ្យជួយស្រង់មនុស្សលង់ទឹក ។ ផ្ទុយមកវិញ ប្រសិនបើយើងមិនមានលទ្ធភាពគ្រប់គ្រាន់នោះទេ (មិនចេះហែលទឹក) ច្បាប់ក៏មិនតម្រូវឱ្យយើងទទួលខុសត្រូវព្រហ្មទណ្ឌដែរ ។ ប៉ុន្តែបើយើងមិនចេះហែលទឹក យើងក៏មិនត្រូវនៅឈរមើលដោយមិនបានធ្វើអ្វីទាំងអស់នោះទេ យើងអាចរត់ទៅហៅអ្នកណា ដែលចេះហែលទឹកឱ្យមកជួយសង្គ្រោះ ឬអាចទៅប្តឹងប៉ូលីសនគរបាលនៅប្រចាំការតាមមូលដ្ឋាន ។ ប្រសិនបើយើងបានខំប្រឹងយ៉ាងសស្រាក់សស្រាំដូច



www.facebook.com/7khmer
fb : Entertainment And Knowledge

នេះហើយ នៅតែមិនអាចជួយសង្គ្រោះអ្នកលង់ទឹកបាន ដោយសារគ្មានអ្នកណានៅជិតនោះ ឬប៉ុស្តិ៍នគរបាលនៅឆ្ងាយ ទើបបណ្តាលឱ្យជនរងគ្រោះលង់ទឹកស្លាប់ទៅ ។ អ្វីដែលចង់បញ្ជាក់នៅចំណុចនេះ គឺថាយើងក៏មិនត្រូវបានគេចោទប្រកាន់ពីបទល្មើសអកម្មទេ ព្រោះយើងបានខំប្រឹងអស់ពីលទ្ធភាពដែរ តែមិនអាចជួយសង្គ្រោះឱ្យទាន់ពេលវេលា ហេតុតែមានឧបសគ្គដូចរៀបរាប់ខាងលើនេះ ។

**គ.៣. បទល្មើសមួយចំនួនស្តែងឡើងជាបទល្មើសអកម្ម (ច្បាប់បារាំង)**

-ការភ្លេចមិនប្តឹងចុះសំបុត្រកំណើតទារក

-ការភ្លេចមិនប្តឹងចុះបញ្ជីរប្រកបមុខរបរសិប្បកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ឬសហគ្រាសទូទៅ

-ការភ្លេច ឬការបំភ្លេច មិនបានទៅផ្តល់សក្ខីភាពចំពោះតុលាការជាប្រយោជន៍ដល់ជនមិនបានប្រព្រឹត្តបទល្មើស

-ការមិនប្តឹងបើកមុខឧក្រិដ្ឋជន

-ការមិនព្រមតំណាងកូនដែលជាអនីតិជន

-ការបោះបង់ ឬមិនផ្តល់អាហារកិច្ចចិញ្ចឹមប្រពន្ធនិងកូនជាអនីតិជន

-ការមិនព្រមជំនុំជំរះក្តីរបស់ចៅក្រម

-ការបង្ខិនបង្ខោចទ្រព្យសម្បត្តិខ្លួនឯង ដើម្បីគេចផុតពីការសងបំណុល

-ការមិនព្រមស្រង់មនុស្សលង់ទឹក,មនុស្សធ្វើអត្តឃាត,មនុស្សរងគ្រោះថ្នាក់ចរាចរណ៍

-ការបង្ករបួសស្នាមដោយអចេតនាបណ្តាលឱ្យស្លាប់ មកពីការធ្វេសប្រហែស ឬមិនគោរពច្បាប់ចរាចរណ៍ ។

**សន្និដ្ឋាន:**

បទល្មើសបានសម្រេច គឺជាបទល្មើសទាំងឡាយណា ដែលជនល្មើស ឬជនដៃដល់បំពេញនូវគោលដៅ ឬគោលបំណងរបស់ខ្លួនបានសម្រេច ហើយបទល្មើសបានសម្រេចនេះ បានបំពេញចិត្តស្របតាមចេតនា ឬឆន្ទៈរបស់ជនល្មើស ឬជនដៃដល់ ដោយផ្តល់នូវ



www.facebook.com/7khmer
fb : Entertainment And Knowledge

បច្ច័យអាក្រក់ ឬផលអាក្រក់ដល់ជនរងគ្រោះ ។ ជាពិសេសបទល្មើសបានសម្រេច បានស្តែងឡើងក្រោមរូបភាពពីរយ៉ាង គឺបទល្មើសសកម្ម និងអកម្ម ។បទល្មើសសកម្មគឺជាសកម្មភាពប្រព្រឹត្តយ៉ាងខិតខំរបស់ជនល្មើសបំពារបំពានលើទំនាក់ទំនងសង្គមដែលនីតិព្រហ្មទណ្ឌខ្មែរបានការពារឬបទល្មើសសកម្មនេះអាចជាអំពើប្រព្រឹត្តកើតឡើងតែមួយភ្លែតក្នុងរយៈពេលដ៏ខ្លីហើយសាមញ្ញ ប៉ុន្តែបទល្មើសនេះក៏អាចអូសបន្លាយពេលវេលាបានដែរ ។ ម្យ៉ាងវិញទៀតវាអាចបណ្តាលឱ្យទទួលរងនូវព្យសនកម្ម(ការខូចខាត)ឬគេហៅបានម្យ៉ាងទៀតថាទំនាក់ទំនងរវាងចំណងហេតុនិងផលឬទំនាក់ទំនងរវាងអំពើប្រព្រឹត្តនិងព្យសនកម្ម។ចំពោះបទល្មើសអកម្មវិញគឺជាបទល្មើសមួយប្រភេទដែលសំដៅទៅលើការមិនបំពេញឬមិនព្រមបំពេញនូវរាល់កាតព្វកិច្ចដែលច្បាប់តម្រូវឱ្យធ្វើហើយយើងមានលទ្ធភាពគ្រប់គ្រាន់នឹងធ្វើ តែយើងបែរជាមិនព្រមបំពេញទៅវិញ ឬមួយយើងក៏បានបំពេញដែរ តែមិនបានពេញលេញតាមការកំណត់របស់ច្បាប់ ឬក៏ភ្លេចបំពេញតែម្តង ។ យ៉ាងណាមិញយើងគួរចងចាំថា ទាល់តែមានច្បាប់ចែងជាក់ថា កាតព្វកិច្ចណាខ្លះ ដែលបុគ្គលគ្រប់រូបក្នុងសង្គម ឬបុគ្គលណាខ្លះត្រូវបំពេញ ហើយនៅពេលអាក់ខានមិនបានបំពេញតាមច្បាប់កំណត់នោះទេ បុគ្គលនេះត្រូវទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌ គឺចង់មានន័យថា បុគ្គលនេះត្រូវតែទទួលខុសត្រូវពីអំពើ ដែលជាបទល្មើស ។

## ផ្នែកទី២ បទល្មើសមិនបានសម្រេច

### ក.និយមន័យ

បទល្មើសមិនបានសម្រេចឬការប៉ុនប៉ងគឺជាបទល្មើស ដែលជនល្មើសបានប្រព្រឹត្តដោយចេតនាដើម្បីសម្រេចគោលបំណងរបស់ខ្លួន ប៉ុន្តែក្នុងពេលប្រព្រឹត្តក៏ត្រូវអាក់ខានទៅវិញដោយសារមានកត្តាផ្សេងៗ មករារាំងមិនឱ្យជនល្មើសប្រព្រឹត្តបានសម្រេច។

មូលហេតុផ្សេងៗ ដែលមកបង្អាក់សកម្មភាពរបស់ជនល្មើសមានដូចជា៖

- ម្ចាស់គេមកទាន់ឬអ្នកដទៃមកទាន់ ឧទាហរណ៍៖ ជនល្មើសឈ្មោះ ក មានបំណងចង់លួចទ្រព្យសម្បត្តិក្នុងផ្ទះរបស់ជនរងគ្រោះឈ្មោះ ខ ។ នៅពេលដែលជនល្មើសឈ្មោះ ក កំពុងតែប្រព្រឹត្តសកម្មភាពគាស់ឬខ្វេះសោផ្ទះដែលជាប់សោស្រាប់តែពេលនោះមានអ្នកជិតខាងនៅក្បែរផ្ទះជនរងគ្រោះមកឃើញទាន់ឬម្ចាស់ផ្ទះផ្ទាល់តែម្តងបានមកឃើញទាន់ចោរកំពុ-



www.facebook.com/7khmer
fb : Entertainment And Knowledge

ងគាស់សោផ្ទះយ៉ាងញាប់ដៃជនល្មើសឈ្មោះ ក ឃើញម្ចាស់ផ្ទះភ័យស្លន់ស្លោបោះចោលប្រដា -ប់ប្រដារគាស់ផ្ទះរួចរត់គេចខ្លួនបាត់ទៅ។

-ឧបករណ៍ដែលជនល្មើសប្រើប្រាស់ខ្វះប្រសិទ្ធភាព។ឧទាហរណ៍ៈជនល្មើសម្នាក់មានបំណងចង់បាញ់សម្លាប់ជនម្នាក់ទៀតដោយប្រើប្រាស់កាំភ្លើងដែលខ្លួនរើសបានតាំងពីសម័យសង្គ្រាម។នៅពេលបម្រុងនឹងប្រព្រឹត្តបទល្មើសជនល្មើសបានដកកាំភ្លើងតម្រង់ទៅជនរងគ្រោះរួចក៏កេះកៃកាំភ្លើងបម្រុងនិងបាញ់ស្រាប់តែពេលនោះកាំភ្លើងបាញ់មិនចេញឬគ្រាប់មិនផ្ទុះដោយហេតុថាកាំភ្លើងនោះវាចាស់ណាស់ទៅហើយគឺវាសល់តាំងតែពីសម័យសង្គ្រាម ដូច្នេះ ទើបវាមិនដំណើរការធ្វើឱ្យជនល្មើសមិនបានសម្រេចតាមបំណងប្រាថ្នា ។

-ជនល្មើសខ្វះទេពកោសល្យ ឧទាហរណ៍ៈ ទាក់ទងនិងការបាញ់កាំភ្លើងនេះដែរ ឧបមាថាជនល្មើសគាត់ចង់សម្លាប់ជនរងគ្រោះដោយប្រើប្រាស់កាំភ្លើងជាអាវុធប្រហារ ។ នៅពេលជនល្មើសលើកកាំភ្លើងបាញ់តម្រង់ទៅជនរងគ្រោះដែល កំពុងដើរស្រាប់តែគាត់បាញ់ខុស ដោយសារជនល្មើស មិនមានជំនាញខាងកាន់កាំភ្លើងបាញ់ ដូចនេះហើយ ទើបជនល្មើសមិនអាចសម្លាប់ជនជនរងគ្រោះបាន ។

បទល្មើសមិនបានសម្រេច គឺជាមូលហេតុដែលអាចនាំឲ្យគេចោទប្រកាន់ពីបទប៉ុនប៉ង ។

## ខ . ការប៉ុនប៉ង ឬ បំណាង

**និយមន័យ:**

ការប៉ុនប៉ង ឬបំណាងគឺជាសកម្មភាពសំដៅទៅលើការប្រព្រឹត្ត ដែលស្ដែងឡើងក្រោមរូបភាព ជាការចាប់ផ្ដើមប្រតិបត្តិហើយមិនបានបញ្ឈប់ការប្រព្រឹត្តដោយចេតនានោះទេ ។

### ខ.១ លក្ខខណ្ឌនៃការប៉ុនប៉ង

តាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌថ្មីរបស់ខ្មែរយើងបានចែងពីចំណុច ដែលជាលក្ខខណ្ឌនៃការប៉ុនប៉ងគឺៈ

– ចារីបានចាប់ផ្ដើមប្រព្រឹត្តបទល្មើសមានន័យថា ចារីបានប្រព្រឹត្តអំពើ ដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស ។



www.facebook.com/7khmer
fb : Entertainment And Knowledge

ឧទាហរណ៍៖ លោក-ក ចង់សម្លាប់លោក-ខ ដោយធ្លាប់មានទំនាស់នឹងគ្នា ។ ថ្ងៃមួយលោក-កចង់វាយលោក-ខ ឱ្យស្លាប់ តែលោក-ខ មិនស្លាប់គឺគ្រាន់តែរបួសធ្ងន់ ។

តាមឧទាហរណ៍ខាងលើយើងឃើញថាបទល្មើសដែលបានកើតឡើង គឺមានលោក-កជាជនល្មើស លោក-ខជាជនរងគ្រោះ។លោក-ក គាត់មានបំណង ឬចេតនាដោយផ្ទាល់ផុសចេញពីចិត្តគ្មានការបង្គាប់បញ្ជាពីអ្នកណាមួយឡើយ ព្រោះដោយសារលោក-ខធ្លាប់មានទំនាស់ជាមួយនឹងខ្លួន ។ ដោយមានចិត្តគុំគួនស្រាប់និងឱកាសហុចឲ្យផងទើបលោក-កសម្រេចចិត្តប្រព្រឹត្តបទល្មើស គឺគាត់មានបំណងចង់សម្លាប់លោក-ខ តែលោក-កត្រូវខកចិត្តព្រោះលោក-ខមិនស្លាប់គ្រាន់តែរបួសធ្ងន់ ។

–ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញ ដោយស្ម័គ្រចិត្តទេតែត្រូវបានរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

ឧទាហរណ៍៖ ទាក់ទងនឹងបទល្មើសខាងលើនេះដែរ នៅពេលលោក-ក វាយសំពងលោក-ខរួច ក៏ដាក់មេប្រូចបាត់ទៅ ។ ត្រង់នេះចង់បញ្ជាក់ថាលោក-កដែលជាជនល្មើស មិនមានឆន្ទៈបញ្ឈប់អំពើប្រព្រឹត្តរបស់ខ្លួននោះទេ គឺថាអំពើប្រព្រឹត្តរបស់គាត់ត្រូវបានអាក់ខានទៅវិញ ដោយសារតែប្រពន្ធកូនលោក-ខ ដែលជាជនរងគ្រោះមកឃើញទាន់ទើបលោក-កភ័យស្លន់ស្លោរត់គេចខ្លួនបាត់ស្រមោល ។ ការដែលប្រពន្ធកូនលោក-ខ មកទាន់នេះហើយ ដែលយើងចាត់ទុកថាជាឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន គឺក្រៅឆន្ទៈរបស់ជនល្មើស ។ ម៉្យាងទៀតដោយកាលៈទេសៈ មិនអំណោយផលបែបនេះហើយ ទើបលោក-ក មិនអាចសម្លាប់លោក-ខ បានដូចចិត្តប៉ង ប៉ុន្តែបើកាលៈទេសៈអំណោយផលវិញ មានន័យថាបើគ្មានប្រពន្ធកូនឬអ្នកឯណាផ្សេងទៀត មកឃើញទាន់នោះទេនោះប្រាកដជាលោក-ខ ត្រូវស្លាប់ក្រោមដៃរបស់លោក-កជាក់ជាមិនខានឡើយ ។

**កំណត់សម្គាល់:**

ការបញ្ឈប់ដោយចេតនា ឬដោយស្ម័គ្រចិត្ត ត្រូវប្រកបដោយលក្ខខណ្ឌពីរគឺ



www.facebook.com/7khmer
fb : Entertainment And Knowledge

-ការបញ្ឈប់នេះត្រូវតែកើតដោយចេតនាមានន័យថាការបញ្ឈប់នេះត្រូវកើតឡើងដោយឆន្ទៈរបស់ជនល្មើសផ្ទាល់ ពុំមែនកើតឡើងដោយមានការគាបសង្កត់ពីខាងក្រៅនោះទេ ។

-ការបញ្ឈប់នេះ ត្រូវកើតឡើងមុនបទល្មើសបានសម្រេចមានន័យថា ការបញ្ឈប់នេះ ត្រូវកើតឡើងនៅមុនពេលអំពើគ្រោះថ្នាក់ដល់សង្គមកើតមានឡើង ឬនៅមុនពេលមិនទាន់ទទួលរងព្យសនកម្ម ។ បើមិនដូច្នោះទេ ពុំមែនជាការបញ្ឈប់ដោយចេតនា ឬដោយស្ម័គ្រចិត្តទេ គឺជាការស្តាយក្រោយដោយសកម្ម មិនមែនជាការស្តាយក្រោយដោយអកម្មនោះទេ ។

ការស្តាយក្រោយដោយសកម្ម គឺជាអំពើរបស់ជនល្មើស ដែលបានខិតខំជួសជុលការអន្តរាយ ដែលបណ្តាលមកពីអំពើរបស់ខ្លួនកន្លងមក ។

ការស្តាយក្រោយដោយអកម្ម គឺជាអំពើដែលជនល្មើសមិនបានជួសជុលព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន ។ ឧទាហរណ៍ទី១៖ ចោរម្នាក់ បានទៅលួចកង់ប៉ះចំយាយចាស់ក្រីក្រ គ្មានអ្វីទីពឹងរស់ដោយសារលក់ត្រកួនដោយមានកង់ជាយានជំនិះ ។ ក្រោយពីចោរលួចកង់គាត់បាត់ លោកយាយកំសត់មានការលំបាកជាខ្លាំង ។ ប៉ុន្តែថ្ងៃក្រោយមកចោរនោះបានយកកង់ទៅសងលោកយាយកំសត់វិញដោយសារចោរមានការអាណិតអាសូរលោកយា-យដែលរស់ដោយសារកង់កញ្ចាស់មួយនឹង។អំពើរបស់ចោរម្នាក់នេះគេហៅថាការស្តាយក្រោយដោយសកម្មព្រោះគាត់បានខិតខំជួសជុលព្យសនកម្ម(សងកង់ទៅលោកយាយវិញ)ដែលបណ្តាលមកពីអំពើរបស់ខ្លួន ។ ឧទាហរណ៍ទី២៖ ចោរម្នាក់បានទៅលួចម៉ូតូរបស់នារីម្នាក់ ។ ក្រោយពី កាច់សោម៉ូតូរួចជិះគេចបាត់ ហើយក៏មានចិត្តអាណិតដែរ ចំពោះនារីនោះ មិនដឹងថានារីនោះជាអ្នកក្រខ្សត់ហើយចោរមិនបានយកម៉ូតូទៅសងនារីនោះវិញទេ។ចោរនោះយក ម៉ូតូទៅលក់យកលុយចាយអស់គ្មានសល់ ។ អំពើរបស់ចោរម្នាក់នេះគេហៅថា ការស្តាយក្រោយដោយអកម្ម ព្រោះថាចោរមិនបានធ្វើអ្វី ដើម្បីជួសជុលនូវព្យសនកម្ម ដែលបណ្តាលមកពីអំពើរបស់ខ្លួននោះទេ ។

ការស្តាយក្រោយដោយសកម្ម និងការស្តាយក្រោយដោយអកម្ម គឺច្បាប់កំណត់ឱ្យផ្តន្ទាទោសដូចគ្នា(ដូចត្រង់ថាត្រូវទទួលរងទោសមិនលើកលែង)គ្រាន់តែថាការស្តាយក្រោយ



www.facebook.com/7khmer
fb : Entertainment And Knowledge

ដោយសកម្ម ជនល្មើសត្រូវតុលាការផ្តល់នូវស្ថានសម្រាលទោស រីឯការស្តាយក្រោយដោយអកម្មវិញ គឺជនល្មើសមិនត្រូវបានតុលាការផ្តល់នូវស្ថានសម្រាលទោស ឬត្រាប្រណីនោះទេ ។

**ចំណាំ**:បទល្មើសប៉ុនប៉ងនិងបទល្មើសបានសម្រេចត្រូវបានផ្តន្ទាទោសដូចគ្នា ដូចមានចែងក្នុងមាត្រា៣១,មាត្រា៣២,មាត្រា៣៣, មាត្រា៣៤នៃច្បាប APRONUC ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ១៩៩២ ។

## ខ.២.ទណ្ឌកម្មនៃការប៉ុនប៉ង

### ខ.២.១:ចំពោះបទឧក្រឹដ្ឋ

ការប៉ុនប៉ងចំពោះបទឧក្រឹដ្ឋគ្រប់ប្រភេទគឺត្រូវតែមានទោសឬត្រូវតែផ្តន្ទាទោសនេះបើយោងតាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌថ្មីរបស់ខ្មែរយើង ។ ដូច្នេះឃើញថាគ្រប់បទល្មើសឧក្រឹដ្ឋទាំងអស់ គឺត្រូវផ្តន្ទាទោសលើការប៉ុនប៉ង ។ គ្មានបទល្មើសឧក្រឹដ្ឋណាមួយ អាចកើតឡើងដោយគ្មានការប៉ុនប៉ងនោះទេ ។ ប្រសិនបើយើងជាជនល្មើសបានប្រព្រឹត្តបទល្មើសណាមួយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មី ហើយត្រូវបាននគរបាលយុត្តិធម៌ចាប់ខ្លួនបានបញ្ជូនទៅតុលាការ ។ ពេលតុលាការជុំនុំជំរះរឿងក្តីនោះប្រាកដជាតុលាការកាត់ក្តីផ្តន្ទាទោសលើការប៉ុនប៉ងហើយ(បទល្មើសមិនបានសម្រេច) ។ នៅពេលយើងប្រកែកថាគ្មានកាប៉ុនប៉ងទេនោះគេពិតជាមិនជឿយើងទេ ព្រោះថាបើយើងគ្មានការប៉ុនប៉ងប្រព្រឹត្តបទល្មើសក៏គ្មានបទល្មើសណាមួយកើតឡើងដែរ។

### ខ.២.២ ចំពោះបទមជ្ឈិម

ការប៉ុនប៉ងក្នុងបទមជ្ឈិម អាចផ្តន្ទាទោសបាន លុះត្រាតែមានចែងជាក់លាក់ក្នុងច្បាប់ យោងតាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌថ្មី ។ ត្រង់នេះចង់មានន័យបញ្ជាក់ថា ដើម្បីអាចផ្តន្ទាទោសលើការប៉ុនប៉ងក្នុងបទមជ្ឈិមណាមួយបាន លុះត្រាតែមានច្បាប់ចែងចង្អុលយ៉ាងច្បាស់លាស់ថា ការប៉ុនប៉ងក្នុងបទមជ្ឈិមណាមួយនោះត្រូវមានទោស ឬត្រូវផ្តន្ទាទោសតាមទម្ងន់នៃបទល្មើសនោះ ។ ផ្ទុយទៅវិញបើគ្មានច្បាប់ចែងថា បទល្មើសមជ្ឈិមណាមួយត្រូវផ្តន្ទាទោសលើការប៉ុនប៉ងនោះទេនោះ គេមិនអាចផ្តន្ទាទោសលើការប៉ុនប៉ងក្នុងបទល្មើសមជ្ឈិមនោះបានទេ ។ ដូច្នេះមុននិងផ្តន្ទាទោសជនល្មើសណាម្នាក់លើការប៉ុនប៉ងក្នុងបទមជ្ឈិមណា



www.facebook.com/7khmer
fb : Entertainment And Knowledge

មួយ គឺគេត្រូវមកមើលក្នុងច្បាប់ជាមុន ប្រសិនបើមានចែងយ៉ាងច្បាស់លាស់ក្នុងច្បាប់នោះ ទើបគេអាចផ្ដន្ទាទោសលើការប៉ុនប៉ងក្នុងបទមជ្ឈិមនេះបាន ។

ឧទាហរណ៍ទី១៖ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសមជ្ឈិមក្នុងផ្នែកបំពានខាងផ្លូវភេទតាមមាត្រា ២៥១ នៃក្រមព្រហ្មទណ្ឌថ្មី ។ នៅក្នុងផ្នែកនេះ បើយើងប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយមាន"បទប្រទូស្តកេរ្តិ៍ខ្មាស់"មាត្រា ២៤៦ "បទបង្ហាញកេរភេទ"មាត្រា ២៤៩ "បទរុកគួនខាងផ្លូវភេទ"មាត្រា ២៥០ នោះ យើងនឹង ត្រូវគេផ្ដន្ទាទោសលើការប៉ុនប៉ងក្នុងបទមជ្ឈិមណាមួយដែលយើងប៉ុនប៉ងប្រព្រឹត្ត ។ បានជាគេអាចផ្ដន្ទាទោសលើការប៉ុនប៉ងក្នុងបទមជ្ឈិមនៃផ្នែកនេះ បានដោយសារមានច្បាប់ចែងយ៉ាងច្បាស់ថា ការប៉ុនប៉ងប្រព្រឹត្តបទល្មើសមជ្ឈិមមានចែងក្នុងផ្នែកនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ មាត្រា ២៥១ នៃក្រមព្រហ្មទណ្ឌថ្មី ។ ដូចយើងឃើញថាមាត្រា ២៥១ នៃក្រមពហ្មទ័ណ្ឌថ្មី របស់យើង គឺជាមាត្រាដែលចងក្រងបទល្មើសមជ្ឈិមក្នុងផែនការបំពានខាងផ្លូវភេទចាប់ពីមាត្រា ២៤៦ ដល់មាត្រា២៥០នៃក្រមព្រហ្មទណ្ឌថ្មី ។

ឧទាហរណ៍ទី២៖ "បទបោះបង់គ្រួសារ"តាមមាត្រា៣២៤នៃក្រមពហ្មទ័ណ្ឌថ្មីមិនមានការប៉ុនប៉ងទេ ពីព្រោះថាច្បាប់មិនមានចែងក្នុងបទល្មើសនេះទេ ដូច្នេះក៏មិនមានផ្ដន្ទាទោសលើការប៉ុនប៉ងក្នុងបទមជ្ឈិមនេះដែរ។

**ខ.២.៣ ចំពោះបទលហុ**

បើយើងមើលទៅមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌថ្មីត្រង់វាក្យខណ្ឌចុងក្រោយបង្អស់ គឺបានចែងយ៉ាងជាក់លាក់ថា "ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្ដន្ទាទោសទេ" ។ ត្រង់ឃ្លានេះចង់មានន័យថា បើបុគ្គលណាមួយបានប្រព្រឹត្តបទលហុ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មី គឺបុគ្គលនោះឯង ពុំត្រូវបានផ្ដន្ទាទោសឬទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើការប៉ុនប៉ងទេដោយសារច្បាប់ មិនមានចែងឲ្យមានការផ្ដន្ទាទោសលើការប៉ុនប៉ងក្នុងបទលហុឡើយ ។

ឧទាហរណ៍៖ លោក-ក បានស៊ីផឹកនៅក្នុងហាងមួយ ។ ពេលស្រវឹងជោគជាំគាត់ក៏ចេញពីហាងជិះម៉ូតូបម្រុងនិងទៅផ្ទះវិញ ។ ភ្លាមនោះស្រាប់តែមានប៉ូលីសមកចាប់គាត់ ដែល



www.facebook.com/7khmer
fb : Entertainment And Knowledge

បំរុងជិះម៉ូតូឡើងផ្លូវជាតិ ។ ប៉ូលីសបានចាប់គាត់ពីបទស្រវឹងជាក់ស្តែងស្របតាមមាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌថ្មី។ត្រង់ចំណុចនេះ គឺថាលោក-ក មិនទាន់ប្រព្រឹត្តបទល្មើសលហុ "បទស្រវឹងជាក់ស្តែង"នៅឡើយទេព្រោះគាត់មិនទាន់ចេញផុតពីហាងផឹកស៊ីនោះទេ ហើយប៉ូលីសក៏មិនអាចផាកពិន័យលោក-ក បានដែរបើប៉ូលីសផាកពិន័យលោក-ក គឺខុសហើយខុសពីគោលការណ៍ច្បាប់ព្រហ្មទណ្ឌព្រោះថាលុះត្រាតែលោក-ក កំពុងស្ថិតនៅលើផ្លូវសាធារណៈ ហើយស្រវឹងផងទើបប៉ូលីសអាចផាកពិន័យគាត់បាន ។

- សម្គាល់: ប្រសិនបើការប៉ុនប៉ងមានការបញ្ឈប់ដោយចេតនា ហើយក្រោយមកគេកត់សម្គាល់ឃើញថា មានបទល្មើសមួយផ្សេងទៀត បានកើតឡើងនោះជនល្មើសត្រូវតែទទួលទោសពីបទល្មើសថ្មីនេះ ។

ឧទាហរណ៍៖ លោក-ក ចង់សម្លាប់លោក-ខ ។ លោក-ក បានទិញកាំភ្លើងធ្វើជាឧបករណ៍ប្រើប្រាស់ក្នុងការសម្លាប់លោក-ខ ប៉ុន្តែដោយមានការអាណិតអាសូរចំពោះប្រពន្ធនិងកូនលោក-ខ ដែលប្រពន្ធជិតគ្រប់ខែសំរាលកូនឯកូនច្បងនៅតូចទៀតធ្វើឲ្យលោក-ក ប្រែចិត្តលែងចង់សម្លាប់លោក-ខ វិញ ហើយបានយកកាំភ្លើងទៅលាក់ទុកនៅក្នុងផ្ទះ ។ ករណីនេះបទល្មើសមិនបានកើតឡើងទេដោយ សារលោក-ក បានបញ្ឈប់ដោយចេតនា ឬដោយការស្ម័គ្រចិត្ត។ក្រោយមកទៀតអាជ្ញាធរមានសមត្ថកិច្ច បានធ្វើការឆែកឆេរនៅផ្ទះលោក-ក ក៏ប្រទះឃើញកាំភ្លើងដែលលោក-ក លាក់ទុកដោយគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់ ឬកាន់កាប់ទេដោយពេលនោះហើយលោក-ក ត្រូវទទួលទោសពីបទល្មើសថ្មី គឺពីបទប្រើប្រាស់អាវុធដោយគ្មានច្បាប់អនុញ្ញាតអនុលោមតាមមាត្រា ៥៩ នៃច្បាប់ APRONUC ឬពីបទកាន់កាប់ដោយគ្មានការអនុញ្ញាតអនុលោមតាមមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌថ្មីរបស់ខ្មែរយើង ។

### គ. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស

បើតាមទ្រឹស្តីជាទូទៅ ស្ថានភាពក្នុងការប្រព្រឹត្តបទល្មើស គេតែងតែបែងចែកដំណាក់កាលនៃការប្រព្រឹត្តបទល្មើសជា ៤ ដំណាក់កាលធំៗ គឺ ៖

–ដំណាកាលទី១ គឺជាដំណាក់កាលនៃការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើស ។

– ដំណាកាលទី២ គឺជាដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស ។



www.facebook.com/7khmer
fb : Entertainment And Knowledge

– ដំណាកាលទី៣ គឺជាដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស ។

–ដំណាកាលទី៤ គឺជាដំណាក់កាលនៃការសម្រេចបទល្មើស ឬបទល្មើសប៉ុនប៉ង (បទល្មើសមិនបានសម្រេចក្លាយជាការប៉ុនប៉ង) ។

នៅក្នុងដំណាក់កាលទាំងបួនខាងលើនេះច្បាប់ មិនមែនផ្តន្ទាទោសនៅគ្រប់ដំណាក់កាលទាំងអស់នោះទេ គឺលុះត្រាតែបទល្មើសស្តែងចេញជារូបរាងមកខាងក្រៅ ហើយបង្កឲ្យមានព្យសនកម្មដល់ចំណុចនេះទើបបានច្បាប់ចែងផ្តន្ទាទោស ។ ដើម្បីឲ្យដឹងថាត្រឹមដំណាក់កាលណាច្បាប់ចែងឲ្យមានការផ្តន្ទាទោស ឬ ត្រឹមដំណាក់កាលណាច្បាប់ចែងមិនទាន់ផ្តន្ទាទោសនោះយើងនិងធ្វើការបកស្រាយគ្រប់ដំណាក់កាលទាំងបួនដូចតទៅ៖

**គ.១ ដំណាក់កាលនៃការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើស**

ដំណាក់កាលនៃការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើស គឺជាដំណាក់កាលទី ១ ។ ដំណាក់កាលនេះ គឺជនល្មើសគ្រាន់តែគិតនៅក្នុងចិត្តតែប៉ុណ្ណោះ ប៉ុន្តែមិនទាន់ចេញជាសកម្មភាពនៅឡើយទេ ។ ក្រោយពីគិតហើយជនល្មើសនិងសម្រេចចិត្តថា ត្រូវប្រព្រឹត្តអំពើល្មើសឬមិនប្រព្រឹត្តទៅវិញអាស្រ័យលើជនល្មើសខ្លួនឯង ។ ប៉ុន្តែអ្វីដែលយើងចង់បញ្ជាក់នៅក្នុងដំណាក់កាលទី១នេះ គឺថាបានជាច្បាប់មិនទាន់ចែងឲ្យផ្តន្ទាទោសចំពោះអ្នក ដែលគិតនិងសម្រេចចិត្តប្រព្រឹត្តបទល្មើសណាមួយគឺមាននូវមូលហេតុពីរជាចម្បងគឺ៖

– ទី១ បទល្មើសនេះមិនទាន់មានរូបរាងច្បាស់លាស់ចេញមកខាងក្រៅ

– ទី២ សង្គមមិនទាន់រងនូវព្យសនកម្ម (ការខូចខាត) ។

ម៉្យាងទៀតបើយើងគិតជានីតិវិធី តើការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើសនេះ តើត្រូវបង្ហាញតាមនីតិវិធី និងភស្តុតាងថាគាត់មានចេតនាប្រព្រឹត្តបទល្មើសយ៉ាងម៉េចនឹងកើត បើគាត់គ្មានការសម្តែងចេញជារូបរាងមកខាងក្រៅជាសម្ភារៈ ដើម្បីកំណត់ឲ្យឃើញពីចេតនាទុច្ចរិតរបស់គាត់ផង ។ ហេតុដូច្នេះហើយ ទើបបានជាច្បាប់អត់ចែងផ្តន្ទាទោសនៅក្នុងស្ថានភាពនេះទេ ។

ឧទាហរណ៍៖មានជម្លោះពាក្យសម្តីមួយរវាងអ្នករាំធុងបាសក្នុងពិធីមង្គលការចុងភូមិមួយ ។ ភាគីម្ខាងឈ្មោះក និងភាគីម្ខាងទៀតឈ្មោះ ខ ។ អ្នកទាំងពីរមានទំនាស់ពាក្យ



www.facebook.com/7khmer
fb : Entertainment And Knowledge

ជាមួយគ្នាដោយលោក-ខ វាំជាន់ជើងលោក-ក ហេតុនេះហើយទើបបណ្តាលឲ្យលោក-ក ខឹងក្តៅស្លឹកត្រចៀករួចឈានទៅដល់ការវាយតបគ្នាកណ្តាលវង់បាស ។ ដោយខាងលោក-ក មានគ្នាច្រើនជាងខាងលោក-ខ ពេលនោះ លោក-ខ ដឹងខ្លួនថាមិនអាចឈ្នះលោក-ក ដោយគេមានគ្នាច្រើនជាង បក្សពួកនិងគូកនលោក-ខ ក៏រត់ចេញពីវង់បាស ហើយត្រឡប់មកផ្ទះវិញ ។ នៅពេលលោក-ខ ត្រឡប់មកផ្ទះវិញគាត់ក៏ចាប់ផ្តើមគិតពីការសងសឹកទៅលើលោក-ក ដែលបានវាយច្រានគាត់ឲ្យចេញពីវង់បាស។បន្ទាប់ពីគិតរួចហើយ លោក-ក ក៏សម្រេចចិត្តថា ត្រូវតែសងសឹកចំពោះបក្សពួកលោក-ក ។ ដោយក្តៅចិត្តត្បិតគេដេញវ៉ៃហើយរត់មិនទាន់ ទាំងបាត់ហាត់ទៀតនោះលោក-ខ ក៏សម្រេចចិត្តត្រូវតែសងសឹកជាដាច់ខាតចំពោះលោក-ក ។ ដូចបានរៀបរាប់ខាងដើមស្រេចថា ក្នុងដំណាក់កាលនេះច្បាប់មិនទាន់ចែងផ្តន្ទាទោសលើលោក-ខ បានទេដោយសារថាអំពើរបស់លោក-ខ គឺស្ថិតក្នុងចិត្តនៅឡើយមិនទាន់ស្តែងចេញជារូបរាងជាសម្ភារៈខាងក្រៅនោះទេហើយ ក៏មិនទាន់មានព្យសនកម្មណាមួយកើតមានចំពោះ លោក-ក ដែរ ។

ម៉្យាងទៀតការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើសលោក-ខ ក៏មិនមែនជាមូលហេតុដែលនាំឲ្យគាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែរ ។

ដូច្នេះយើងឃើញថាដំណាក់កាលទី ១ ឬដំណាក់កាលនៃការគិតនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើសគឺច្បាប់មិនទាន់ចែងផ្តន្ទាទោសនៅឡើយទេ ។ យើងនិងសិក្សាទៅលើដំណាក់កាលទី ២ គឺដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើសបន្តទៀត ៖

**គ.២ ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស**

ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើសជាដំណាក់កាលទី ២ គឺជនដែលបម្រុង នឹងប្រព្រឹត្តបទល្មើសដែលពួកគេមានត្រៀមជាឧបករណ៍ ដើម្បីសម្រួលឲ្យការប្រព្រឹត្តបទល្មើសមានប្រសិទ្ធភាព ។ ត្រង់ដំណាក់កាលទី ២ នេះផងដែរក៏មិនទាន់កើតមានទាំងជនល្មើសដែរ ព្រោះថាមិនទាន់កើតមានទាំងជនរងគ្រោះ ទាំងព្យសនកម្មដល់ជនរងគ្រោះនឹងសង្គម ។ ម៉្យាងទៀតក្នុងស្ថានភាពបែបនេះ រូបរាងរបស់បទល្មើស ដែលស្តែងចេញមកខាងក្រៅក៏មិនទាន់ច្បាស់ ទោះបីជាមានការសម្រេចចិត្តក៏ពិតមែន ប៉ុន្តែជនដែលប្រព្រឹត្ត



www.facebook.com/7khmer
fb : Entertainment And Knowledge

បទល្មើសក៏អាចនិងផ្លាស់ចិត្តគំនិតឬប្តូរទិសដៅរបស់គេផងដែរ ។ ដោយហេតុនេះហើយទើបច្បាប់មិនទាន់កំណត់ឲ្យផ្តន្ទាទោសចំពោះអំពើត្រៀមទុករបស់ជន ដែលបម្រុងប្រព្រឹត្តបទល្មើសដោយយល់ថាអំពើត្រៀមរបស់ជននេះ មិនទាន់មានព្យសនកម្មណាមួយបានកើតឡើងចោទជាបញ្ហាដល់សង្គមនោះទេ ។

ឧទាហរណ៍:ទាក់ទងនឹងឧទាហរណ៍ខាងលើដដែលក្រោយពីលោក-ខនឹងសងសឹកជាដាច់ខាតចំពោះលោក-កដែលជាគូវិវាទរបស់ខ្លួន។ពេលនោះហើយដែល លោក-ខ បានទៅទិញកាំបិតខ្វែវមួយបំណាងយកកាំបិតនេះធ្វើជាឧបករណ៍ផ្តាច់ជីវិតលោក-ក ។ ជារៀងរាល់ថ្ងៃលោក-ខ តែងតែទៅពិនិត្យស្ថានភាពចេញចូលរបស់លោក-ក ថាលោក-ក យប់ឡើងចូលផ្ទះម៉ោងប៉ុន្មាន ធ្វើដំណើរតាមផ្លូវណាដើរលេងនៅកន្លែងណាខ្លះ ។ ដូច្នេះឃើញថាស្ថានភាពបែបនេះគឺជាការត្រៀមរៀបចំប្រព្រឹត្តបទល្មើសរបស់លោក-ខ ព្រោះថាគាត់បានត្រៀមជាឧបករណ៍គឺកាំបិតខ្វែវដែលគាត់ទិញហើយសំលៀងរួចជាស្រេចដើម្បីសំរួលនូវការប្រព្រឹត្តបទល្មើសឲ្យមានប្រសិទ្ធភាពគាត់ក៏បានត្រៀមលក្ខណៈដើម្បីស្គាល់យល់ដឹងអំពីស្ថានភាពភូមិសាស្ត្រ អំពីសកម្មភាពប្រចាំថ្ងៃរបស់លោក-ក ផងដែរ ។ អំពើរបស់លោក-ខ នៅពេលនេះ គឺច្បាប់មិនទាន់កំណត់ថា ជាបទល្មើសនៅឡើយទេដោយសារមិនទាន់មានជនរងគ្រោះ មិនទាន់មានព្យសនកម្មណាមួយកើតឡើងនិយាយឲ្យចំលោក-ក ដែលជាគូវិវាទរបស់លោក-ខគឺគាត់មិនទាន់រងនូវព្យសនកម្មណាមួយបណ្តាលមកពីអំពើររបស់លោក-ខ នៅឡើយទេ ។ ដូច្នេះហើយច្បាប់ មិនបានតម្រូវឲ្យលោក-ខ ទទួលខុសត្រូវព្រហ្មទណ្ឌ ឬផ្តន្ទាទោសលោក-ខ ទោះលោកបានសំលៀងកាំបិតរួចហើយក៏ដោយជូនកាលលោក-ខ អាចនិងប្តូរចិត្តគំនិតថ្មីហើយអាចយកកាំបិត ដែលគាត់សំលៀងរួចនោះទៅធ្វើអ្វីផ្សេង ដែលមិនមែនជាបទល្មើសដូចដែលគាត់បានគ្រោងទុកពីមុនមក។ក៏ប៉ុន្តែប្រសិនបើលោក-ខ កំពុងសំលៀងកាំបិតហើយបញ្ចេញជាពាក្យសម្តីរគំរាមគំហែងដល់លោក-កថាខ្លួននិងទៅដើម្បីនឹងសម្លាប់ម្តងហើយម្តងទៀតមិនដាច់ពីមាត់ ករណីនេះអាចលេចចេញជាបទល្មើសថ្មីមួយទៀតដាច់ដោយឡែកខុសពីបទល្មើសពីមុន គឺវាអាចចូលទៅក្នុងករណីមួយហៅថាបទគំរាមគំហែង



www.facebook.com/7khmer
fb : Entertainment And Knowledge

ដែលមានចែងនៅក្នុងមាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌថ្មី ។ ដូចនេះលោក-ខ អាចជាប់ទោសពីបទល្មើសថ្មី(បទគំរាមគំហែង) ប៉ុន្តែមិនទាក់ទងនឹងរឿងដើមនោះទេ ។

- កំណត់សម្គាល់: មានករណីលើកលែងខ្លះដែលច្បាប់បានចែងឲ្យមានការផ្តន្ទាទោសអំពីស្ថានភាពនោះតែម្តងដោយយល់សំអាងថាការត្រៀមប៉ុណ្ណឹងសំខាន់ឲ្យតែស្តែងចេញមកជារូបរាងជាសម្ភារៈមកខាងក្រៅដែលនាំឲ្យគេអាចកំណត់បានគឺចាត់ទុកជាបទល្មើ-សហើយ។ចំណុចនេះគឺច្បាប់ព្រហ្មទណ្ឌរបស់យើងប្រើសម្រាប់តែបទល្មើសណា ដែលមានលក្ខណៈធ្ងន់ធ្ងរ ហើយផ្តល់ព្យសនកម្មខ្លាំងដល់សង្គមជាតិ ។

ឧទាហរណ៍៖ ករណីបទល្មើសដែលមានចែងក្នុងមាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌថ្មី គឺ"បទឧបឃាត" ត្រង់វាក្យខណ្ឌទី១បានចែងថា "ឧបឃាត គឺជាការប្រព្រឹត្តអំពើហឹង្សាមួយ ឬច្រើនក្នុងគោលបំណងបង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឲ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ" ។ យើងឃើញថា បទឧបឃាតនេះជាករណីបទល្មើសធ្ងន់ធ្ងរព្រោះវាអាចផ្តល់នូវព្យសនកម្មធំធេង ដល់សង្គមក៏ដូចជាប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថាប័នរដ្ឋដូចជាទាក់ទងនិងអំពើភេរវកម្មជាដើម ។ ឧបមាជនល្មើសមានបំណងចង់ដាក់គ្រាប់បែកបំផ្ទុះបំផ្លាញអាគាររាជរដ្ឋាភិបាល(ទីស្តីការគណៈរដ្ឋមន្ត្រី)បើសិនជាយើងទប់ស្កាត់មិនទាន់ពេលវេលាទេនោះអំពើភេរវកម្មពិតជាផ្តល់នូវព្យសនកម្មយ៉ាងធំធេងជាមិនខានឡើយ។ ដោយសារបទឧបឃាតជាបទល្មើសធ្ងន់ធ្ងរដែលមានចែងយ៉ាងច្បាស់ត្រង់មាត្រា ៤៥១ ដដែលវាក្យខណ្ឌទី ២ "បទឧបឃាតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ។បទល្មើសនេះគេមិនចាំបាច់ដល់លេចចេញជាបទល្មើសជាក់ស្តែងនោះទេឲ្យតែសកម្មភាពដែលលេចចេញអាចឲ្យគេកំណត់បានដូចជាការបញ្ជាទិញគ្រឿងអាវុធជាតិផ្ទុះលក្ខណៈធំដុំនិងមានការរៀបចំជាកម្លាំងពិសេសច្បាស់លាស់ករណីនេះឯង គេអាចចាត់ជាបទល្មើសហើយត្រូវផ្តន្ទាទោសតែម្តង ។

សរុបមកក្នុងដំណាលទី ២ នេះបើចូលក្នុងករណីពិសេស ដែលច្បាប់ចែងអំពីសកម្មភាពត្រៀមណាមួយ ដែលត្រូវធ្វើការផ្តន្ទាទោស ដើម្បីធានានូវផលប្រយោជន៍សាធារណៈ ទើបច្បាប់ថាមានបទល្មើសកើតឡើងហើយ ។ ផ្ទុយទៅវិញខុសពីករណីពិសេស គឺទូទៅ



www.facebook.com/7khmer
fb : Entertainment And Knowledge

ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើសគឺថា ច្បាប់មិនទាន់ចាត់ទុកជាបទល្មើសនៅឡើយទេ ហើយច្បាប់ព្រហ្មទណ្ឌក៏មិនបានចូលធ្វើអន្តរាគមន៍លើអំពើត្រៀមនេះដែរ ។

**គ.៣ ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស**

ក្រោយពីបានបកស្រាយនូវដំណាក់កាលទី ១ និង ដំណាក់កាលទី២ រួចមកនៅចំណុចនេះយើងនឹងធ្វើការបកស្រាយចូលដល់ដំណាក់កាលទី ៣ នៃការប្រព្រឹត្តបទល្មើស ។ នៅដំណាក់កាលទី ៣ នេះខុសប្លែកពីដំណាក់កាលមុនៗ(ដំណាក់កាលទី ១ និងដំណាក់កាលទី ២) ចង់ដឹងថាវាខុសប្លែកគ្នាដូចម្តេចខ្លះក្រុមខ្ញុំនឹងព្យាយាមបកស្រាយតាមតែអាចធ្វើបាន ។

នៅដំណាក់កាលទី៣ ឬ ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស[២] ដំណាក់កាលប្រតិបត្តិ[៣] គឺជនល្មើសចាប់ផ្តើមចេញធ្វើសកម្មភាពតាមការគ្រោងទុក ដើម្បីសម្រេចបំណងឧក្រិដ្ឋរបស់ខ្លួនហើយអាចផ្តល់នូវព្យសនកម្ម (ការខូចខាត) ដល់ជនរងគ្រោះផងដែរ ។

ឧទាហរណ៍៖ ពាក់ព័ន្ធនិងរឿងរ៉ាវរបស់លោក-ក និងលោក-ខ ដដែល គឺថាក្រោយពីបានត្រៀមជាឧបករណ៍ (កាំបិតខ្វែវ) រួចជាស្រេចហើយ លោក-ខ ក៏បានចាំពួនស្ទាក់វាយប្រហារលោក-ក ដែលតែងតែធ្វើដំណើរទៅមកមិនលោះតាមផ្លូវដែលលោក-ខ កត់សម្គាល់យ៉ាងច្បាស់ ។ នៅពេលលោក-ក ជិះម៉ូតូមកដល់ចំណុចដែលលោក-ខ ចាំពួនស្ទាក់ភ្លាម នោះលោក-ខ ក៏ចេញមកពីក្នុងព្រៃហើយដកកាំបិតពីក្រោយខ្នងលើកកាប់ចាក់ប្រហារលើលោក-ក ទៅ ។ ត្រង់ចំណុចនេះយើងឃើយថាលោក-ខ បានបញ្ចេញសកម្មភាពប្រព្រឹត្តបទល្មើសរបស់គាត់ឲ្យឃើញជាក់ច្បាស់ហើយលោក-ក ក៏ទទួលរងព្យសនកម្មផងដែរ ។

**គ.៤ ដំណាក់កាលនៃការសម្រេចបទល្មើស ឬ បទល្មើសប៉ុនប៉ង (បទល្មើសមិនបានសម្រេចក្លាយជាការប៉ុនប៉ង)**

ដំណាក់កាលនៃការសម្រេចបទល្មើស ឬ បទល្មើសប៉ុនប៉ង (បទល្មើសមិនបានសំរេចក្លាយជាការប៉ុនប៉ង)គឺជាដំណាក់ទី៤ ឬ ជាដំណាក់កាលចុងក្រោយបំផុតនៃការប្រព្រឹត្តបទ

[២] **សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែររបស់សាស្ត្រាចារ្យ កៅ សីហា**

[៣] **សៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់សាស្ត្រាចារ្យ ផាត់ ពៅស៊ាង**



www.facebook.com/7khmer
fb : Entertainment And Knowledge

ល្មើស ។ ដំណាក់កាលនេះគឺជនល្មើសអាចទទួលបានលទ្ធផលពីរយ៉ាងគឺ ៖

–ទី ១ ប្រសិនបើលទ្ធផលនៃការប្រព្រឹត្តបទល្មើសបាន បំពេញតាមបំណងរបស់ជនល្មើស ហើយស្របតាមចេតនា ដែលជនល្មើសចង់បាននោះយើងហៅ ករណីនេះថា "បទល្មើសបានសម្រេច" ។

ឧទាហរណ៍៖លោក-ក ចង់សម្លាប់លោក-ខ ដោយសារទំនាស់រឿងស្នេហាត្រីកោណរវាងខ្លួន (លោក-ក) និងលោក-ខ ជាមួយនារី-គ ។ លោក-ខ ជាមនុស្សដែលនារី-គ ស្រលាញ់ឯលោក-កវិញ នារី-គ មិនស្រលាញ់ទេគឺគ្រាន់តែរាប់អានជាមិត្តធម្មតា ។ ដោយខកចិត្តនឹងរឿងស្នេហា លោក-ក ក៏មានគំនិតទុច្ចរិតហើយចង់សម្លាប់លោក-ខ ដែលជាគូរប្រជែងស្នេហ៍របស់ខ្លួន ។ នៅថ្ងៃមួយពេលមានឪកាសហុចឲ្យ លោក-ក បានយកកាំបិតមុតស្រួចទៅចាក់លោក-ខ ៥កាំបិត ក្នុងគោលបំណងចាក់សំលាប់លោក-ខ រួចគេចខ្លួនបាត់ ។ ចំពោះលោក-ខ វិញ ដែលជាជនរងគ្រោះ ក្រោយពីត្រូវលោក-ក ដែលជាជនល្មើសចាក់ចំនួន ៥កាំបិត ហូរឈាមខ្សោះខ្លួនហើយប្រកាច់ដេកដួលរហូតស្លាប់បាត់បង់ជីវិតទៅ ។

តាមឧទាហរណ៍នេះយើងឃើញថា លោក-ក ជនល្មើសបានសម្រេចបំណងរបស់ខ្លួនដោយជោគជ័យមានន័យថាលោក-កចង់ឲ្យលោក-ខស្លាប់ក្រោយពី អំពើល្មើសកើតឡើងហើយជាលទ្ធផលលោក-ខ ជាជនរងគ្រោះបានស្លាប់ប្រាកដមែន នេះជាករណីបទល្មើសបានសម្រេច។

–ទី ២ ផ្ទុយមកវិញប្រសិនបើលទ្ធផលនៃការប្រព្រឹត្តបទល្មើសមិនបានបំពេញតាមបំណង ឬឆន្ទៈរបស់ជនល្មើសនោះទេ ដោយគ្រាន់តែផ្ដល់នូវព្យសនកម្ម (ការខូចខាត) ធ្ងន់ធ្ងរឬស្រាលដល់ជនរងគ្រោះយើងហៅបទល្មើសនោះថាជាការប៉ុនប៉ង ។

ឧទាហរណ៍៖ ទាក់ទងរឿងហេតុខាងលើដដែល ឧបមារថាក្រោយពីលោក-ក បានចាក់ទៅលើលោក-ខ ចំនួន៥កាំបិត រួចមកលោក-ខ ក៏ត្រូវបានអ្នកជិតខាង ជួយយកទៅសង្គ្រោះនៅមន្ទីពេទ្យបានទាន់ពេលវេលា ។ ដូចនេះហើយលោក-ខ ក៏បានរួចរស់ជីវិតពីការស្លាប់ដោយគ្រាន់តែរបួសដេកពេទ្យតែប៉ុណ្ណោះ ។ ត្រង់ចំណុចនេះយើងអាចនិយាយបានថា



www.facebook.com/7khmer
fb : Entertainment And Knowledge

លោក-ក ដែលជាជនល្មើសត្រូវខកចចិត្តព្រោះថាសម្លាប់លោក-ខ មិនបានសម្រេចគ្រាន់តែរបួសធ្ងន់ ។

ដូច្នេះនៅក្នុងដំណាក់កាលទី ៤ នេះ ច្បាប់បានចែងផ្តន្ទាទោស តែនៅលើ ស្ថានភាពដែលយើងអាចនិយាយជារួម គឺមានបទល្មើស២ប្រភេទគឺ ៖

1. បទល្មើសបានសម្រេច
2. បទល្មើសប៉ុនប៉ងដែលបានបំពេញលក្ខខណ្ឌនៃការប៉ុនប៉ង[៤] ដែលត្រូវផ្តន្ទាទោស ។

**សន្និដ្ឋាន៖**

បទល្មើសមិនបានសម្រេច ឬការប៉ុនប៉ង គឺជាបទល្មើស ដែលជនល្មើសបានប្រព្រឹត្តដោយចេតនា ដើម្បីសម្រេចគោលបំណងរបស់ខ្លួន ប៉ុន្តែក្នុងពេលប្រព្រឹត្តក៏អាក់ខានទៅវិញដោយសារមានកត្តាផ្សេងៗ មករារាំងមិនឱ្យសម្រេចដូចជាម្ចាស់គេមកទាន់ ឬអ្នកដទៃមកទាន់ ។ បទល្មើសមិនបានសម្រេច ជាមូលហេតុដែលនាំឱ្យគេចោទប្រកាន់ពីបទប៉ុនប៉ង ។ បទប៉ុនប៉ងនេះត្រូវផ្តន្ទាទោសទៅតាមកម្រិតនៃទោសដែលត្រូវចោទប្រកាន់។ក៏ប៉ុន្តែដើម្បីអាចផ្តន្ទាទោសលើការប៉ុនប៉ងបាន លុះត្រាតែបំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់នៃការប៉ុនប៉ង ។ជាទូទៅ គេបានបែងចែកដំណាក់កាលនៃការប្រព្រឹត្តបទល្មើសជាបួនដំណាក់កាល ហើយច្បាប់ក៏បានចែងថាត្រូវផ្តន្ទាទោសត្រឹមដំណាក់កាលទី ៣ និង ដំណាក់កាលទី ៤(ករណីទូទៅ) ។ ផ្ទុយមកវិញ ក្នុងករណីពិសេសច្បាប់បានតម្រូវឲ្យផ្តន្ទាទោសតាំងពីដំណាក់កាលទី ២ ព្រោះថាករណីពិសេសនេះគឺពាក់ព័ន្ធទៅនឹងប្រភេទបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរដូចជា បទភេរវកម្មជាដើម បើពុំមានការទប់ស្កាត់ឲ្យទាន់ពេលវេលានោះទេពិតជាផ្តល់នូវព្យសនកម្មយ៉ាងធំធេងដល់សង្គមជាតិទាំងមូលជាក់ជាមិនខាន ។ ហេតុដូច្នេះហើយទើបបានជាច្បាប់ចែងឲ្យផ្តន្ទាទោសចំពោះដំណាក់កាលទី ២ នេះដើម្បីបញ្ចៀសនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ប្រទេស ។

[៤] **សូមមើលចំណុចខ.១ "លក្ខខណ្ឌនៃការប៉ុនប៉ង"**



www.facebook.com/7khmer
fb : Entertainment And Knowledge

## សេចក្តីសន្និដ្ឋានរួម

សរុបជារួមមកយើងឃើញថានៅក្នុងធាតុសត្យានុម័តឬធាតុសម្ភារៈនេះគឺមានគោលបំណងបង្ហាញពីបទល្មើសមួយតាមរយៈសកម្មភាពខាងក្រៅដែលជនល្មើសបានប្រព្រឹត្ត ហើយមានសាធារណៈជនបានឃើញផងដែរ ។បើយើងសិក្សាឲ្យបានស៊ីជម្រៅ នៅក្នុងធាតុសត្យានុម័ត ឬ ធាតុសម្ភារៈគឺត្រូវបានបែងចែកជាពីរផ្នែក ទី១ មាននិយាយអំពីបទល្មើសបានសម្រេច ទី២ មាននិយាយអំពីបទល្មើសមិនបានសម្រេច ឬ ដែលយើងហៅថាការប៉ុនប៉ង។ បទល្មើសបានសម្រេច គឺនៅពេលដែលជនល្មើសបានសម្រេចនូវគោលបំណាង ឬ ឆន្ទៈរបស់ខ្លួនក្នុងការប្រព្រឹត្តបទល្មើសណាមួយ ហើយវាបានបង្កឲ្យមានព្យសនកម្ម(ការខូចខាត)ដល់ជនរងគ្រោះទោះធ្ងន់ ឬ ស្រាលក្តី ។ មិនតែប៉ុណ្ណោះបទល្មើសបានសម្រេច ក៏ផ្តល់នូវផលវិបាកដល់សង្គមជាតិ ដោយបង្កជាអំពើអសន្តិសុខ បាត់បង់របៀបរៀបរយសាធារណៈនិងអំពើអសកម្មផ្សេងៗតាមរយៈអំពើសកម្ម(បទល្មើសសកម្ម) និង អំពើអកម្ម(បទល្មើសអកម្ម)ដែលជនល្មើសបានប្រព្រឹត្ត ។ ចំពោះបទល្មើសមិនបានសម្រេច ឬ ការប៉ុនប៉ងវិញចារី ឬ ជនដៃដល់បានខិតខំប្រឹងប្រែងប្រព្រឹត្តបទល្មើសយ៉ាងសកម្ម តាមរយៈការប្រើនូវឧបាយកលមធ្យោបាយផ្សេងៗដើម្បីឲ្យខ្លួនអាចសម្រេចបាននូវគោលដៅក៏ដូចជាបំណងប្រាថ្នាដែលខ្លួនចង់បាន ប៉ុន្តែទន្ទឹមនឹងនោះស្រាប់តែមានឧបសគ្គមករារាំង ឬ កាលៈទេសៈមិនអំណោយផលទើបចារី ឬ ជនដៃដល់មិនអាចប្រព្រឹត្តបទល្មើសបានសម្រេច ហើយត្រូវខកចិត្តយ៉ាងខ្លាំង ។ទោះជាយ៉ាងណាក្តីបទល្មើសមិនបានសម្រេច ក៏មិនត្រូវបានគេបំភ្លេចចោល ឬ មើលរំលងឡើយគឺនឹងត្រូវចូលជាបទប៉ុនប៉ងដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៧របស់ព្រះរាជាណាចក្រកម្ពុជាយើង ។ យ៉ាងណាមិញ ការប៉ុនប៉ងមិនថាក្នុងបទឧក្រិដ្ឋ បទមជ្ឈឹម ឬ បទលហុនឹងត្រូវឲ្យផ្តន្ទាទោសបានលុះត្រាតែបំពេញនូវរាល់លក្ខខណ្ឌដែលច្បាប់បានកំណត់ ឬ ដល់ដំណាក់កាលណាមួយដែលច្បាប់បានកំណត់ថាអាចចាត់ចូលជាបទល្មើសហើយតម្រូវឲ្យជនដែលប្រព្រឹត្តបទល្មើសនោះចាំបាច់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ។ដូច្នេះដើម្បីឲ្យយល់កាន់តែច្បាស់ យើងគួរបកទៅមើលនៅផ្នែកខាងដើមវិញ ព្រោះថាចំណុចទាំងអស់នោះក្រុមរបស់ខ្ញុំបានធ្វើការបកស្រាយរួចមកហើយថាលក្ខខណ្ឌអ្វីខ្លះ ឬ ដល់ដំណាក់កាលណាដែលត្រូវមានទោសឬជាប់ក្នុងបទប៉ុនប៉ងដែលច្បាប់ព្រហ្មទណ្ឌខ្មែរបានកំណត់។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ឯកសារយោង

១. ក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ ២០០៩ ។

២. សៀវភៅមេរៀនស្តីអំពី **នីតិព្រហ្មទណ្ឌទូទៅ** របស់សាស្ត្រាចារ្យ **ឡាយ ណូរ៉ា** ។

៣. សៀវភៅ **នីតិព្រហ្មទណ្ឌទូទៅខ្មែរ** របស់សាស្ត្រាចារ្យ **កៅ សីហា** ។

៤. សៀវភៅ **នីតិព្រហ្មទណ្ឌទូទៅ** របស់សាស្ត្រាចារ្យ **ផាត់ ពៅស៊ាង** ។

៥. សៀវភៅ **នីតិព្រហ្មទណ្ឌទូទៅ** របស់សាស្ត្រាចារ្យ **ហ៊ាង ឡេង** ។

៦. សៀវភៅ **នីតិព្រហ្មទណ្ឌទូទៅ** របស់សាស្ត្រាចារ្យ **រុន ពុណ្ណារិទ្ធិ** ។

៧. ប្រសាសន៍ របស់សាស្ត្រាចារ្យ **ឡាយ ណូរ៉ា** ។

៨. ប្រសាសន៍ របស់សាស្ត្រាចារ្យ **កៅ សីហា** ។



www.facebook.com/7khmer
fb : Entertainment And Knowledge